ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)
**លេខាធិការដ្ឋាន**

លេខៈ ០៦៩៥៨៧/គ.ជ.អ.ប

រាជធានីភ្នំពេញ, ថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៣

**គោរពជូន**

**ឯកឧត្តមប្រធានក្រុមការងារគ្រប់គ្រង និងអនុវត្តអនុកម្មវិធីនៃ ផ.អ.៣**
**និងឯកឧត្តមអភិបាលរាជធានី ខេត្ត**

**__កម្មវត្ថុ__** : ការអនុវត្តចំណាយចំពោះថវិកាផ្ទេរលើកទីមួយសម្រាប់ឆ្នាំ២០១៣ និងការធ្វើរបាយការណ៍ហិរញ្ញវត្ថុប្រចាំខែមកលេខាធិការដ្ឋាន គ.ជ.អ.ប ។

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំសូមជម្រាបឯកឧត្តមមេត្តាជ្រាបថា ដើម្បីជួយសម្រួលដល់ការអនុវត្តសកម្មភាពប្រតិបត្តិការរបស់អនុកម្មវិធី និងរាជធានី ខេត្តក្នុងក្របខណ្ឌផែនការអនុវត្តរយៈពេល០៣ឆ្នាំនៃកម្មវិធីជាតិ លេខាធិការដ្ឋាន គ.ជ.អ.ប បានផ្ទេរថវិកាជំហានដំបូងចំនួន ២៥១.០០០,០០ ដុល្លារសហរដ្ឋអាមេរិក (ពីររយហាសិបមួយពាន់ដុល្លារសហរដ្ឋអាមេរិក) ជូនដល់អនុកម្មវិធី និងរាជធានី ខេត្ត។ លេខាធិការដ្ឋាន គ.ជ.អ.ប សូមណែនាំអំពីការអនុវត្តចំណាយ និងការរៀបចំរបាយកាណ៍ ដូចខាងក្រោម ៖

**១.ការអនុវត្តចំណាយ**

- ដោយមិនទាន់មានសេចក្ដីសម្រេចរួម អនុកម្មវិធី និងរាជធានី ខេត្តត្រូវធានាថា ការចំណាយត្រូវធ្វើឡើងក្នុងក្របខណ្ឌ ចំណាយប្រតិបត្តិការតែប៉ុណ្ណោះ ដោយមិនឱ្យលើសពីកម្រិតចំណាយប្រតិបត្តិការដែលមានក្នុងពង្រាងផែនការសកម្មភាព និងថវិកាឆ្នាំ២០១៣។
- ការចំណាយខាងលើ ត្រូវបម្រើដល់ការសម្រេចនូវលទ្ធផលរំពឹងទុកដែលឯកភាពដោយលេខាធិការដ្ឋាន គ.ជ.អ.ប ។

ចំពោះការចំណាយលើសកម្មភាពធំៗ អនុកម្មវិធី និងរាជធានី ខេត្តត្រូវរៀបចំសំណើមកលេខាធិការដ្ឋាន គ.ជ.អ.ប ដោយភ្ជាប់មកជាមួយនូវសំណើសុំគោលការណ៍អនុវត្តសកម្មភាព និងមានការបញ្ជាក់ថា សកម្មភាពនោះស្ថិតនៅក្នុងសេចក្ដីព្រាងស្ដីពីផែនការសកម្មភាព និងថវិកាសម្រាប់ឆ្នាំ២០១៣។

**២.ការរៀបចំរបាយការណ៍**

រាជធានី ខេត្ត និងអនុកម្មវិធីត្រូវរៀបចំរបាយការណ៍ហិរញ្ញវត្ថុប្រចាំខែឱ្យបានត្រឹមត្រូវ និងបញ្ជូនមកលេខាធិការដ្ឋាន គ.ជ.អ.ប យ៉ាងយូរបំផុតត្រឹមកំឡុងសប្ដាហ៍ទី២នៃខែបន្ទាប់ ដើម្បីជៀសវាងក្នុងការផ្ទេរថវិកាមានភាពយឺតយ៉ាវនៅជំហានបន្ទាប់ ដែលជាហេតុធ្វើឱ្យប៉ះពាល់ដល់ការអនុវត្តសកម្មភាពរបស់រាជធានី ខេត្ត និងអនុកម្មវិធី។



មហាវិថីព្រះនរោត្តមៈ លេខាធិការដ្ឋាននៃគ.ជ.អ.ប ក្រសួងមហាផ្ទៃ ។ ទូរស័ព្ទ: (៨៥៥-២៣) ៧២០ ០៦១ / ៧២០ ០៣៨ E-mail: info@ncdd.gov.kh Website: www.ncdd.gov.kh
Norodom Blvd., National Committee for Sub-National Democratic Development Secretariat (NCDDS). Ministry of Interior. Tel: (855-23) 720 061 / 720 038

ទម្រង់របាយការណ៍ហិរញ្ញវត្ថុប្រចាំខែរួមមាន ៖

- ទិន្នានុប្បវត្តចំណូល ។
- ទិន្នានុប្បវត្តចំណាយ ។
- គណនីសៀវភៅធំ ។
- បញ្ជីសង្ខេបចំណាយតាមខ្ទង់ថវិកា ប្រភពធនធាន និងសេចក្តីសម្រេចរួម ។
- តារាងផ្ទៀងផ្ទាត់គណនីធនាគារដោយមានភ្ជាប់សម្រង់ធនាគារក្នុងការិយបរិច្ឆេទជាក់លាក់ ។
- តារាងលំហូរសាច់ប្រាក់ ។
- បញ្ជីសង្ខេបប្រតិបត្តិការបុរេប្រទាន ។
- បញ្ជីសង្ខេបមូលប្បទានបត្រពុំទាន់ដកប្រាក់ ។
- តារាងផ្ទៀងផ្ទាត់គណនី ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមមេត្តាចាត់ចែងអនុវត្តសេចក្តីជូនដំណឹងនេះប្រកបដោយប្រសិទ្ធភាពខ្ពស់ ។

សូមឯកឧត្តមមេត្តាទទួលនូវការគោរពរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ ។

**៤. ប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប**